ACCESS
Sustainable quality services for all

Australian Aid




# កម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជាដើម្បីការផ្តល់សេវាប្រកបដោយនិរន្តរភាព និងសមធម៌ (ហៅកាត់ ACCESS) ក្នុងខេត្តកំពង់ស្ពឺ

កម្មវិធី ACCESS គឺជាកម្មវិធីដែលស្ថិតក្រោមការផ្តួចផ្តើម និងគាំទ្រដោយរដ្ឋាភិបាលអូស្ត្រាលីក្នុងគោលដៅពង្រឹងនិរន្តរភាព គុណភាព និងបរិយាបន្នសេវាសម្រាប់ជនមានពិការភាព និងស្ត្រីរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

## តួលេខសំខាន់ៗក្នុងខេត្តកំពង់ស្ពឺ *

**២១%** អត្រាស្ត្រីដែលមានអាយុចន្លោះពី១៥ទៅ៤៩ឆ្នាំ ដែលធ្លាប់ទទួលរងអំពើហិង្សាផ្លូវកាយ

**៥,១%** ការប៉ាន់ប្រមាណនៃអត្រាប្រេវ៉ាឡង់ពិការភាព ក្នុងចំណោមប្រជាជនដែលមានអាយុចាប់ពី ៥ឆ្នាំឡើងទៅ

**PRC DPOs** មានមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា (PRC) មួយ និងអង្គការជនពិការ (DPOs) មួយចំនួន កំពុងតែផ្តល់ការគាំទ្រចាំបាច់នានាដល់ជនមានពិការភាពក្នុងខេត្ត

*ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០១៤

## ដៃគូរបស់កម្មវិធី ACCESS

- អាជ្ញាធរនៅថ្នាក់ខេត្ត ស្រុក ឃុំ និងភូមិ
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត
- មន្ទីរសុខាភិបាលខេត្ត និងមូលដ្ឋានសុខាភិបាល

### ផ្នែក GBV

- មន្ទីរកិច្ចការនារីខេត្ត
- តុលាការខេត្ត/ក្រុង
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារថ្នាក់ខេត្ត និងស្រុក
- អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC)
- អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC)
- អង្គការសហប្រជាជាតិសម្រាប់ស្ត្រី (UNW)

### ផ្នែកពិការភាព

- ក្រុមប្រឹក្សាសកម្មភាពជនពិការខេត្ត និងស្រុក (ក.ស.ជ)
- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត
- សាខាមូលនិធិជនពិការខេត្ត និងPRC
- មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត
- សាខាក្រុមហ៊ុនអេីដ្យាយល៍ ឌីវេឡុមមិន គ្រុប (Agile)
- អង្គការជនពិការកម្ពុជា (អ.ព.ក)
- ចំរើនម៉ាយក្រូហ្វាយនែន
- អង្គការ HI
- អង្គការឡៃហ្វ៍រឌឺវើល (LFTW)
- កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)

ACCESS
Sustainable quality services for all

Australian Aid

កម្មវិធី ACCESS ធ្វើការជាដៃគូជាមួយរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអនុវត្ត សំដៅចូលរួមចំណែកក្នុងការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (NAPVAW) និងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព (NDSP)។

## សកម្មភាព

### ការលុបបំបាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ

- អភិវឌ្ឍសមត្ថភាពរបស់សមាជិក និងបង្កើនចំនួនក្រុមការងារ GBV ទៅស្រុកថ្មីចំនួនបួន។
- បណ្តុះបណ្តាលពីបទដ្ឋាន និងគោលការណ៍ណែនាំទាក់ទងនឹងកញ្ចប់សេវា GBV។
- បណ្តុះបណ្តាលដល់ភ្នាក់ងារ/មន្ត្រីនគរបាលយុត្តិធម៌ មេធាវី និងភាគីពាក់ព័ន្ធផ្នែកសម្រុះសម្រួល។
- ពង្រឹងការផ្តល់សេវាផ្លូវច្បាប់ និងគាំទ្រដល់ភាគីនានាក្នុងការសម្រុះសម្រួល និង/ឬការបញ្ជូន។
- កសាងសមត្ថភាពរបស់ដៃគូក្នុងស្រុកដើម្បីផ្តល់សេវាសង្គមនានា៖ ជម្រកសុវត្ថិភាព ប្រឹក្សាជាមូលដ្ឋាន គាំទ្រផ្នែកផ្លូវចិត្តសង្គម និងព្យាបាល។

### ការពង្រឹងសិទ្ធិអំណាចដល់ជនមានពិការភាព

- ពង្រឹងសមត្ថភាព ក.ស.ជ. ខេត្តដើម្បីផ្តល់ការសម្របសម្រួល និងធ្វើការតាមដានមើលការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព។
- គាំទ្រដល់ការអនុវត្តបទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព។
- គាំទ្រដល់យន្តការផ្នែកការងារ និងមុខរបរដើម្បីធ្វើឱ្យប្រសើរឡើងដល់ការសម្របសម្រួល និងការបញ្ជូន។
- គាំទ្រដល់ការធ្វើបរិយាបន្នពិការភាពនៅតាមមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងកន្លែងការងារ។
- លើកកម្ពស់ភាពជឿជាក់លើខ្លួនឯង និងជំនាញរបស់ជនមានពិការភាពក្នុងការស្វែងរកឱកាសការងារ និងមុខរបរ។
- គាំទ្រដល់សហគ្រិនភាពរបស់ជនមានពិការ។

### ការធានាបាននូវនិរន្តរភាព និងគុណភាពសេវា

- កសាងសមត្ថភាពរបស់អង្គភាពថ្នាក់ក្រោមជាតិនៃក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក.ស.ជ. ស្តីពីដំណើរការនៃការរៀបចំផែនការថវិកាស្របតាមការណែនាំពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- គាំទ្រដំណើរការដាក់បញ្ចូលសកម្មភាពអាទិភាពនៃ NAPVAW និងNDSP ទៅក្នុងផែនការថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិរួមទាំងផែនការវិនិយោគឃុំ។


**ទំនាក់ទំនង**

អាសយដ្ឋាន៖ អគារអានីណា ជាន់ទី៣ បន្ទប់២៤០ ផ្លូវ២៧១ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទ៖ (៨៥៥) ១២ ៨៧៦ ៥៤៩
អ៊ីមែល៖ info@accesscambodia.org
ព័ត៌មានបន្ថែម៖ www.accesscambodia.org